កិច្ចជួយបន្ថែមទៀតសំរាប់ជួយគ្រួសាររបស់លោកអ្នក

លោកអ្នកប្រហែលជាអាចទទួលកិច្ចជួយដទៃទៀតដើម្បីជួយចំពោះលោកអ្នកនិងគ្រួសារ នៅក្នុងពេលដែលលោកអ្នកនៅក្នុងគោលបំណងនៃកម្មវិធី Cal-Learn របស់លោកអ្នក ។ កិច្ចជួយជាបន្ថែមទៀតអាចមានគិតបញ្ចូលទាំង :

WIC

កម្មវិធីជួយចំពោះស្ត្រី ទារក និងកូនក្មេងដែលគេស្គាល់ថាកម្មវិធី WIC គឺជាកម្មវិធីផ្តល់ម្ហូបអាហារ និងជីវជាតិបន្ថែមដែលអាចផ្តល់ជូនលោកអ្នកនូវការសិក្សាអប់រំផ្នែកជីវជាតិនៃអាហារ ម្ហូបអាហារដែលជួយឱ្យមានសុខភាពល្អ និងការឱ្យឱវាទផ្នែកបំបៅកូននឹងទឹកដោះ ។

បណ្ណទិញម្ហូប

តាមរយៈកម្មវិធីនេះ លោកអ្នកអាចទទួលនូវជំនួយដើម្បីទិញម្ហូបអាហារសំរាប់គ្រួសាររបស់លោកអ្នក ។

Medi-Cal (ជំនួយផ្នែកពេទ្យនៃរដ្ឋកាលីហ្វ័រនីញ៉ា)

តាមរយៈកម្មវិធី Medi-Cal លោកអ្នកអាចទទួលនូវការថែរក្សាសុខភាពនៅមុនពេលសំរាលកូន និងការឆែកពិនិត្យនៅពេលបន្ទាប់ពីសំរាលកូនរួចមក ។ លោកអ្នកក៏អាចមានសិទ្ធិទទួលនូវការថែរក្សាសុខភាពទូទៅនិងថែរក្សាធ្មេញផងដែរ ។ ទារករបស់លោកអ្នកក៏អាចទទួលនូវជំនួយពេទ្យដូចជា ការចាក់ថ្នាំបង្ការរោគ និងកិច្ចថែរក្សាទារកឱ្យបានល្អផងដែរ ។

កិច្ចជួយផ្នែកគ្រោងការគ្រួសារ

នៅពេលដែលទារករបស់លោកអ្នកសំរាលមក លោកអ្នកអាចពិចារណាអំពីការជ្រើសរើសកិច្ចការពារកំណើតកូនរបស់លោកអ្នក ។ កិច្ចជួយផ្នែកគ្រោងការគ្រួសារដោយឥតគិតថ្លៃ ឬដោយអស់ប្រាក់បន្តិចបន្តួចអាចមានផ្តល់ជូនចំពោះលោកអ្នក ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចជួយលោកអ្នកសំរេចចិត្តថាតើកិច្ចការពារកំណើតកូនមួយណាដែលប្រសើរបំផុតសំរាប់លោកអ្នក ។ គឺជាការសំខាន់ ក្នុងការសំគាល់ថា ស្ត្រីអាចមានផ្ទៃពោះនៅក្នុងពេលដែលគេកំពុងបំបៅកូនរបស់គេ ។

កិច្ចជួយដទៃទៀតអាចមានផ្តល់ជូន ។ សូមពិភាក្សាជាមួយអ្នកចាត់ការសំណុំរឿងរបស់លោកអ្នកសំរាប់ពត៌មាន និងកិច្ចជួយជាបន្ថែម ។

Reach For Your Dreams

With Cal-Learn

សំរាប់ពត៌មានបន្ថែមអំពីកម្មវិធី Cal-Learn សូមទាក់ទងទៅ :

Flex your POWER

© 2001 State of California

Energy conservation tips available at: www.flexyourpower.ca.gov

STATE OF CALIFORNIA រដ្ឋកាលីហ្វ័រនីញ៉ា
Arnold Schwarzenegger, អភិបាលរដ្ឋ
HEALTH AND HUMAN SERVICES AGENCY
ក្រសួងសុខភាពនិងមនុស្សភាព
S. Kimberly Belshé, រដ្ឋលេខាធិការ
CALIFORNIA DEPARTMENT OF SOCIAL SERVICES
ក្រសួងសង្គមកិច្ច

PUB 367 (CB) (1/04)

លោភយក ការស្រមៃរបស់លោកអ្នក

ជាមួយកម្មវិធី Cal-Learn



កម្មវិធីសំរាប់រដ្ឋទាំងមូល សំរាប់អ្នកទទួលជំនួយពីកម្មវិធី CalWORKs/TANF អាចជួយក្មេងជំទង់ដែលមានផ្ទៃពោះនិងជាឪពុកម្តាយឱ្យបញ្ចប់សាលាមធ្យមភ្ញា ក្លាយទៅជាអ្នកគ្រប់គ្រងខ្លួនដោយខ្លួនឯង និងឱ្យក្លាយទៅជាគ្រួសារប្រកបទៅដោយសុខភាពល្អ ។

Reach For Your Dreams

With Cal-Learn

តើ Cal-Learn គឺជាអ្វី?

Cal-Learn គឺជាកម្មវិធីសំរាប់ស្ត្រីទាំងមូលសំរាប់ក្មេងជំទង់ដែលមានផ្ទៃពោះ និងជាមាតាបិតា ទាំងឪពុកនិងម្តាយ ដែលជាអ្នកទទួលជំនួយ CalWORKs/TANF ។ នេះមិនមែនជាសាលារៀនទេ ។ គោលបំណងនៃកម្មវិធី Cal-Learn គឺដើម្បីជួយចំពោះក្មេងជំទង់ឱ្យទទួលសញ្ញាបត្រមធ្យមសិក្សា ក្លាយទៅជាអ្នកទទួលខុសត្រូវដោយខ្លួនឯង និងរៀបចំជាគ្រួសារដែលមានសុខភាពប្រសើរមួយ ។

តើខ្ញុំត្រូវតែចូលរួមឬ?

បើសិនជាលោកអ្នកកំពុងទទួលជំនួយ CalWORKs/TANF លោកអ្នកត្រូវតែចូលរួមជាមួយកម្មវិធី Cal-Learn ។ក្មេងជំទង់ខ្លះអាចក្លាយទៅជាអ្នកទទួលការលើកលែងពីកម្មវិធី ឬពន្យារនូវការចូលរួមនៅក្រោមកាលៈទេសៈពិសេស ។

ដើម្បីមានសិទ្ធិចូលរួមជាមួយកម្មវិធី Cal-Learn លោកអ្នកត្រូវ :

- រស់នៅក្នុងក្រុមគ្រួសារតែមួយជាមួយកូនរបស់លោកអ្នក
- ត្រូវមានអាយុតិចជាង១៩ឆ្នាំ
- មិនទាន់មានសញ្ញាបត្រមធ្យមសិក្សា ឬសញ្ញាបត្រវិជ្ជាទូទៅ (GED)
- មិនរស់នៅក្នុងបន្ទុកនៃការចិញ្ចឹមថែកូនក្មេងចិញ្ចឹម

ការទទួលនូវប្រាក់ឆ្នាន់ឬការធ្វើទណ្ឌកម្ម

Cal-Learn ផ្តល់ជារង្វាន់សំរាប់ការមានចំណាត់ថ្នាក់ល្អ និងធ្វើទណ្ឌកម្មចំពោះការពុំមានចំណាត់ថ្នាក់ល្អប្រសើរ ។

ត្រូវធ្វើឱ្យបានល្អប្រសើរនិងទទួលនូវរង្វាន់

- ការបានទទួលនូវចំណាត់ថ្នាក់ល្អ និងផ្តល់សេចក្តីថ្លែងការចំណាត់ថ្នាក់នៅពេលដែលគេបានចេញឱ្យ = $100 ត្រូវបានបន្ថែមទៅលើប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកសំរាប់កំឡុងពេលនៃការផ្តល់សេចក្តីរាយការណ៍ចំណាត់ថ្នាក់នីមួយៗ ។
- ការទទួលសញ្ញាបត្រមធ្យមក្សិា = $500 សំរាប់លោកអ្នក ។

ការធ្វើមិនបានល្អ និងទទួលទណ្ឌកម្ម :

- ទទួលចំណាត់ថ្នាក់ក្រោមមធ្យមD និងការមិនបានផ្តល់ឱ្យនូវសេចក្តីថ្លែងការចំណាត់ថ្នាក់នៅពេលដែលគេបានចេញឱ្យ = $100 ត្រូវបានដកចេញពីប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកសំរាប់កំឡុងពេលនៃការផ្តល់សេចក្តីរាយការណ៍ ចំណាត់ថ្នាក់នីមួយៗ ។

សំរាប់ពត៌មានបន្ថែម

សំរាប់ពត៌មានយ៉ាងល្អិតល្អន់អំពីការចូលរួមនៅក្នុងកម្មវិធី Cal-Learn សូមនិយាយជាមួយបុគ្គលិកនៃកម្មវិធី Cal-Learn នៅក្នុងខណ្ឌរបស់លោកអ្នក ។

ការទទួលសញ្ញាបត្ររបស់លោកអ្នក

នៅពេលដែលលោកអ្នកនៅក្នុងកម្មវិធី Cal-Learn លោកអ្នកនឹងបានទទួលអ្នកចាត់ការលើសំណុំរឿង ដែលនឹងជួយលោកអ្នករៀបចំគ្រោងការដើម្បីបញ្ចប់មធ្យមសិក្សា ឬទទួលសញ្ញាបត្រ GED ។ បើសិនជាលោកអ្នកនៅក្នុងពេលបច្ចុប្បន្ន មិនទៅសាលារៀនទេ អ្នកចាត់ការលើសំណុំរឿងរបស់លោកអ្នកនឹងជួយលោកអ្នកឱ្យវិលត្រឡប់ទៅសាលារៀនវិញ ឬស្វែងរកសាលារៀនដែលត្រូវទៅនឹងសេចក្តីត្រូវការរបស់លោកអ្នក ។

ក្មេងជំទង់នៃកម្មវិធី Cal-Learn ម្នាក់ៗនឹងដំណើរការតាមកម្មវិធីដូចៗគ្នា :

- **ការប៉ាន់ប្រមាណ** : ដើម្បីធ្វើការកំណត់ថាតើកិច្ចជួយ ការផ្គត់ផ្គង់ណាដែលលោកអ្នកត្រូវការ ដើម្បីលោកអ្នកអាចបំពេញនូវគោលបំណងនៃការសិក្សាអប់រំរបស់លោកអ្នក ។
- **ការបង្កើតជាគ្រោងការ** : ដើម្បីលោកអ្នកអាចទទួលនូវកិច្ចជួយដែលលោកអ្នកត្រូវការនិងចូលសាលារៀន ។ គោងការ៍នឹងបង្ហាញផងដែរនូវអ្វីដែលអ្នកកាន់សំណុំរឿងរបស់លោកអ្នកនឹងធ្វើជូនលោកអ្នក និងអ្វីដែលលោកអ្នកនឹងធ្វើសំរាប់ខ្លួនឯង ។
- **ការធ្វើសកម្មភាព** : លោកអ្នកនឹងអ្នកចាត់ការលើសំណុំរឿងរបស់លោកអ្នកនឹងធ្វើការនៅលើគ្រោងការរបស់លោកអ្នក រៀបចំលោកអ្នកតាមផ្លូវដែលលោកអ្នកអាចទៅដល់គោលបំណងរបស់លោកអ្នកសំរាប់ខ្លួននិងគ្រួសាររបស់លោកអ្នក ។
- **ការតាមដាន** : ដើម្បីឱ្យបានជាក់ច្បាស់ថាលោកអ្នកមានការរីកចំរើនឆ្ពោះទៅកាន់សញ្ញាបត្រ ឬ GED របស់លោកអ្នក និងបំពេញទៅតាមគោលបំណងដទៃទៀត ។
- **ការពិនិត្យមើលលើគ្រោងការក្នុងពេលយូរៗម្តង** : ដើម្បីបញ្ជាក់មើលលើអ្វីដែលមានដំណើរការល្អ និងអ្វីដែលមិនដំណើរការ ។

Reach For Your Dreams
With Cal-Learn

ការចាត់ចែងសំណុំរឿងដើម្បីជោគជ័យ

អ្នកចាត់ការលើសំណុំរឿងរបស់លោកអ្នកនឹងជួយចំពោះលោកអ្នកដោយមិនត្រឹមតែកិច្ចទៅសាលារៀនតែប៉ុណ្ណោះទេ ។ គាត់ប្រហែលជាអាចជួយផ្តល់ជូនលោកអ្នកនូវកិច្ចជួយផ្គត់ផ្គង់មួយចំនួនធំដែលអាចជួយលោកអ្នកបំពេញនូវបញ្ហាដែលលោកអ្នកមាន ដែលជាឪពុកម្តាយជាក្មេងជំទង់ដោយធ្វើការមួយទល់នឹងមួយជាមួយលោកអ្នក ឪពុកឬម្តាងម្នាងទៀតនៃកូនរបស់លោកអ្នក និងក្រុមគ្រួសាររបស់លោកអ្នកទាំងមូល ។

សូមនិយាយជាមួយអ្នកចាត់ការលើសំណុំរឿងរបស់លោកអ្នកសំរាប់ពត៌មានបន្ថែមអំពីកិច្ចជួយណែនាំសំខាន់ទាំងនេះ :

កិច្ចជួយផ្គត់ផ្គង់

អ្នកចាត់ចែងលើសំណុំរឿងរបស់លោកអ្នកអាចផ្តល់ជូនលោកអ្នកនូវការណែនាំឱ្យទៅជួបភ្នាក់ងារដទៃទៀតដែលអាចជួយចំពោះបញ្ហាផ្សេងៗដែលលោកអ្នកជួបប្រទះ ដោយគិតបញ្ចូលទាំង :

- បញ្ហាផ្នែកផ្លូវច្បាប់
- អំពើឃោរឃៅនៅក្នុងគ្រួសារ
- បញ្ហាសុខភាព
- ផ្នែកផ្ទះសំបែង

ការចំណាយសំរាប់ថែរក្សាក្មេង

កម្មវិធី Cal-Learn អាចជួយចំពោះលោកអ្នកសំរាប់កិច្ចថែរក្សាក្មេងនៅក្នុងពេលលោកអ្នកទៅសាលារៀន ។ បើសិនជាលោកអ្នកធ្វើការនិងទៅសាលារៀន លោកអ្នកអាចមានសិទ្ធិទទួលកិច្ចថែរក្សាក្មេងនៅក្នុងពេលដែលលោកនៅធ្វើការ ។

ការចំណាយសំរាប់ឃានដឹកនាំ

លោកអ្នកប្រហែលជាអាចទទួលជំនួយសំរាប់បង់ថ្លៃឃានដឹកនាំទៅនិងមកពីសាលារៀន ។

ការចំណាយសំរាប់សាលារៀន

តម្លៃសំរាប់ការប្រឡងយកសញ្ញាបត្រ GED សៀវភៅ និងមន្ទីរពិសោធន៍គឺជាមុខរបស់ខ្លះដែលកម្មវិធី Cal-Learn អាចជួយលោកអ្នកទិញសំរាប់សាលារៀន ។